សិល្បៈខ្មែរអមតៈ

With the support of

United Nations Educational, Scientific and Cultural Organization

Diversity of Cultural Expressions

# សេចក្តីប្រកាសព័ត៌មាន

## អ្នកដឹកនាំ ក្នុងពីវិស័យវប្បធម៌នៅក្នុងប្រទេសកម្ពុជា រួមគ្នាបង្កើតសមាគមលក្ខណៈអាជីពមួយ សម្រាប់ឧស្សាហកម្មច្នៃប្រឌិត និងវប្បធម៌ សម្រាប់កម្ពុជា ក្រោមការគាំទ្រពី មូលនិធិអន្តរជាតិ សម្រាប់ភាពផ្សេងៗគ្នានៃវប្បធម៌ របស់អង្គការយូណេស្កូ

**រាជធានីភ្នំពេញ, ២៤ ឧសភា ២០២១ -** ក្រោមមូលនិធិអន្តរជាតិ សម្រាប់ភាពផ្សេងៗគ្នានៃវប្បធម៌របស់អង្គការយូណេស្កូ ថ្នាក់ដឹកនាំអង្គការសិល្បៈជាច្រើន បានរួបរួមគ្នាបង្កើតសមាគមផ្អែកលើសមាជិកភាពមួយ ដើម្បីជួយសម្របសម្រួលនិងតស៊ូមតិសម្រាប់វិស័យឧស្សាហកម្មច្នៃប្រឌិតនិងវប្បធម៌ នៅកម្ពុជា។

នៅដើមឆ្នាំ ២០២០ នៅពេលការប៉ះពាល់សង្គមនិងសេដ្ឋកិច្ច ដែលបង្កឡើងដោយជម្ងឺឆ្លង កូដវីដ បានចាប់វាយលុកវិស័យវប្បធម៌នៅកម្ពុជា អ្នកគ្រប់គ្រងនិងដឹកនាំអង្គការសិល្បៈជាច្រើនបានធ្វើការរួមគ្នា ដោយព្យាយាមប្រមូលព័ត៌មាននិងអនុសាសន៍នានា ដើម្បីដាក់ជូនដល់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នូវអ្វីដែលជាតម្រូវការចាំបាច់សម្រាប់ជួយដល់សិល្បករ ឱ្យឆ្លងផុតពីស្ថានភាពដ៏យ៉ាប់យ៉ឺនមួយនេះ។

លោក ហួត តារា ជានាយកប្រតិបត្តិ នៃសហគ្រាសសិល្បៈសង្គមហ្វារ និងជាប្រធានស្តីទីនៃគណៈស្ថាបនិករបស់សមាគម បានមានប្រសាសន៍ថា ប្រាសាទ របាំ ពិធីទំនៀមនានា ពិធីបុណ្យ ស្ថាបត្យកម្ម ។ល។ និង ។ល។ ជាសម្បត្តិវប្បធម៌របស់យើង ដែលបានជួយយើងដែលជាប្រជាជនកម្ពុជា ឱ្យស្គាល់ខ្លួនឯងជានរណា។ ទោះជាយ៉ាងនេះក្តី វិស័យឧស្សាហកម្មច្នៃប្រឌិត និងវប្បធម៌របស់កម្ពុជា មិនទាន់ត្រូវបានគេឱ្យតម្លៃ ថាជាកត្តាចម្បងសម្រាប់ជម្រុញការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់កម្ពុជានៅឡើយទេ ពីព្រោះរាល់សកម្មភាពទាំងអស់របស់យើង ត្រូវបានគេចាត់ទុកថាជារឿងបន្ទាប់បន្សំរបស់វិស័យឧស្សាហកម្មផ្សេងៗទៀតដូចជា វិស័យទេសចរណ៍ តែប៉ុណ្ណោះ។

ដោយមានការចាប់ផ្តើមអាជីពការងារដំបូងរបស់លោក ក្នុងវិស័យទេសចរណ៍ លោក ហួត តារា បានទទួលបទពិសោធន៍ដោយផ្ទាល់ អំពីសារប្រយោជន៍នៃការមានសមាគមសម្របសម្រួលកណ្តាលមួយ ដែលអាចជួយ ពិនិត្យមើល វាស់វែង គាំទ្រ និងតស៊ូមតិ ឱ្យវិស័យមួយ។ ភ្លាមនោះ បំណងនៃធ្វើការរួមគ្នា ក៏ចាប់ផ្តើមមានឡើង។

ដោយធ្វើជាតំណាងឱ្យក្រុមការងារមួយនេះ អង្គការសិល្បៈខ្មែរអមតៈ ក៏បានរៀបចំដាក់ពាក្យស្នើដល់មូលនិធិអន្តរជាតិ សម្រាប់ភាពផ្សេងៗគ្នានៃវប្បធម៌ របស់អង្គការយូណេស្កូ ហើយក៏ត្រូវបានជ្រើសជាគម្រោងមួយក្នុងចំណោមគម្រោងទាំងប្រាំមួយ ហើយការជ្រើសរើសនេះ ត្រូវបានធ្វើឡើងចេញពីពាក្យស្នើសុំជាងមួយពាន់ពាក្យដែលអង្គការយូណេស្កូទទួលបានជុំវិញពិភពលោក។

ឥឡូវនេះ ចាប់តាំងពីថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០២១ មក អង្គការសិល្បៈខ្មែរអមតៈ រួមជាមួយនឹងសហដឹកនាំនៃសមាជិកគណៈស្ថាបនិក ដែលមាន៖

- លោក ហួត តារា នាយកប្រតិបត្តិ នៃសហគ្រាសសិល្បៈសង្គមហ្វារ (ប្រធានស្តីទី)
- អ្នកស្រី អុន សុខនី នាយកប្រចាំប្រទេស នៃអង្គការអេពិកអាតស៍
- លោក អូស្មាន់ ខ្វារ៉ាចា នាយកប្រតិបត្តិ នៃសមាគមហ្វារពន្លឺសិល្បៈ
- លោក ជា សុភាព នាយក នៃមជ្ឈមណ្ឌលសោតទស្សន៍បុប្ផាណា
- អ្នកស្រី សូ ភីណា ប្រធានកម្មវិធីចំណេះ បណ្តាញ និងគោលនយោបាយ នៃអង្គការសិល្បៈខ្មែរអមតៈ ជាសមាជិក
- កញ្ញា ឡូ៉ា ម៉ម ចាងហ្វាង នៃផលិតកម្មបារមី

កំពុងតែធ្វើការរួមគ្នា ដើម្បីផ្តើមបង្កើតសមាគម។ នៅពេលសមាគម ត្រូវបានចុះបញ្ជីរួច (ដែលគ្រោងនឹងចុះបញ្ជីរួចរាល់នៅក្នុងខែកញ្ញា) នោះវានឹងក្លាយទៅជាសមាគមឯករាជ្យមួយ ហើយនិងប្រតិបត្តិការងាររបស់ខ្លួន ជាសមាគមមួយផ្អែកលើសមាជិកភាព ក្រោមការដឹកនាំរបស់គណៈកម្មាធិការនាយក ដែលមានមហាសន្និបាតប្រចាំឆ្នាំ សម្រាប់រាយការណ៍ជូន ក៏ដូចជាការធ្វើការសម្រេចចិត្ត ចេញពីសមាជិករបស់ខ្លួនផងដែរ។

ការចូលជាសមាជិករបស់សមាគម អាចចូលជាលក្ខណៈបុគ្គល ឬជាលក្ខណៈអង្គការ ដោយឯករាជ្យ ឬ ផ្លូវការ។ គណៈស្ថាបនិក ក៏សូមស្វាគមន៍ចំពោះអស់លោកអ្នក ដែលមានចំណាប់អារម្មណ៍ចង់ចូលរួមនៅក្នុងដំណាក់កាលដំបូងនេះផងដែរ។ ប្រសិនបើមានចំណាប់អាមរម្មណ៍ សូមធ្វើការទំនាក់ទំនងមក cci@cambodianlivingarts.org ។

លោក ហួត តារា ដែលជាស្ថាបនិកផង និងជាប្រធានស្តីទី នៃគណៈស្ថាបនិកផង បានមានប្រសាសន៍ថា ខ្ញុំសប្បាយចិត្តនិងមានកិត្តិយសក្នុងការដឹកនាំកិច្ចខិតខំប្រឹងប្រែងនៅដំណាក់កាល់ដំបូងនេះ ដោយធ្វើការរួមគ្នាជាមួយមិត្តរួមវិស័យមកពីអង្គការនិងស្ថាប័នវប្បធម៌នានាអ្នកពាក់ព័ន្ធនិងអ្នកបង្កើតគោលនយោបាយ , ទាំងឡាយក្នុងការជួយអភិវឌ្ឍវិស័យឧស្សាហកម្មច្នៃប្រឌិតនិងវប្បធម៌នៅកម្ពុជា។ ខ្ញុំរង់ចាំដោយក្តីរីករាយនូវការបង្កើតនិងការចាប់ផ្តើមដំណើរការរបស់សមាគមផ្អែកលើសមាជិកភាពមួយនេះ ដែលនឹងស្វាគមន៍ចំពោះអ្នកទាំងឡាយណាដែលមានចំណាប់អារម្មណ៍ចូលរួមជាសមាជិក ឬជាអ្នកស្ម័គ្រចិត្តនៅក្នុងគណៈកម្មាធិការនាយក ដើម្បីចូលរួមក្នុងការងាររបស់សមាគម។

ក្នុងអំឡុងពេលពីរឆ្នាំ នៃការផ្តល់មូលនិធិនេះ សមាគមធ្វើការលើសកម្មភាពជាក់លាក់មួយចំនួន ដែលក្នុងនោះមានរួមមាន គម្រោងស្រាវជ្រាវ ដើម្បីបង្ហាញពីផ្នែកក្រៅផ្លូវការនៃឧស្សាហកម្មច្នៃប្រឌិតនិងវប្បធម៌នានា។ វាមានសារៈសំខាន់ណាស់ ដោយសារសិល្បករនិងសិប្បករជាច្រើននាក់ មិនទាន់ត្រូវគេរាប់បញ្ចូលឱ្យបានពេញលេញនៅក្នុងផ្នែកសេដ្ឋកិច្ច ហើយមិនទាន់មានព័ត៌មាននិងធនធានដែលពួកគេមានសិទ្ធិទទួលបាននៅឡើយ។ ឧទាហរណ៍ដូចជា សិទ្ធិក្នុងការទទួលបាន បសស ឬសិទ្ធិស្តីពីច្បាប់កិច្ចសន្យា។ ការស្រាវជ្រាវ នឹងត្រូវបានប្រើប្រាស់ ដើម្បីបង្កើតជាអនុសាសន៍ ជូនដល់ក្រសួងពាក់ព័ន្ធ ពីរបៀបនៃពង្រឹងលក្ខខណ្ឌក្នុងការផ្តល់ការគាំទ្រ

បន្ថែមទៅដល់អ្នកធ្វើការក្នុងការងារសិល្បៈ និងការងារច្នៃប្រឌិត ហើយដើម្បីធ្វើរឿងហ្នឹងទៅបាន គឺត្រូវពង្រឹងនិងអភិវឌ្ឍបន្ថែមអំពីការយល់ដឹងនិងទីផ្សារសម្រាប់ការងាររបស់ពួកគេ។ សមាគម នឹងធ្វើការលើគម្រោងថ្មីផ្សេងៗផងដែរ ក្រោមការណែនាំរបស់សមាជិកពាក់ព័ន្ធរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងទិន្នន័យជាក់ស្តែង ដែលសមាគមនឹងធ្វើការប្រមូលនិងវិភាគ ជុំវិញវិស័យឧស្សាហកម្មច្នៃប្រឌិតនិងវប្បធម៌។

នៅក្នុងរយៈកាលពីរឆ្នាំនេះផងដែរ អង្គការសិល្បៈខ្មែរអមតៈ នឹងអនុវត្តកម្មវិធីអាហារូបករណ៍ទស្សនវប្បធម៌ចំនួនពីរលើក ដែលជាកម្មវិធីកសាងសមត្ថភាពនៃភាពជាអ្នកដឹកនាំក្នុងវិស័យសិល្បៈ។ កម្មវិធីអាហារូបករណ៍ សម្រាប់ឆ្នាំ ២០២២ នឹងមានការផ្តោតជាពិសេសលើគោលនយោបាយវប្បធម៌ និងដើម្បីធ្វើការជាមួយអ្នកដែលនឹងទទួលតួនាទីដឹកនាំសមាគម។

លោក ព្រឹម ភឿន នាយកប្រតិបត្ត របស់អង្គការសិល្បៈខ្មែរអមតៈ បានមានប្រសាសន៍ថា អង្គការសិល្បៈខ្មែរអមតៈ មានកិត្តិយស ដែលខ្លួនអាចបម្រើសហគមន៍សិល្បៈ តាមរយៈចូលរួមផ្តើមឱ្យមានការបង្កើតសសមាគមនេះឡើង។ ពួកយើងជឿជាក់ថា សង្គមមួយអាចរីកចម្រើនពេញលេញទៅបាន ដោយមានការចូលរួមពីសិល្បៈ ហើយវាច្បាស់ថា ការងាររបស់សិល្បករ និងអ្នកដែលធ្វើការក្នុងវាស័យឧស្សាហកម្មច្នៃប្រឌិតនិងវប្បធម៌ ដោយរាប់បញ្ចូលតាំងពីការសម្តែង សិប្បកម្ម ភាពយន្ត និងតន្ត្រីដែលបង្កើតដោយមិនចម្លងពីអ្នកដទៃ ចូលរួមចំណែកយ៉ាងច្រើនសម្រាប់សេដ្ឋកិច្ចកម្ពុជា ក៏ដូចជាភាពល្បីរន្ទឺទាំងក្នុងប្រទេសនិងអន្តរជាតិ។ សមាគមន ដែលតំណាងឱ្យវិស័យដ៏សំខាន់នេះ មានសក្តានុពល ក្នុងការធ្វើឱ្យការងារ ឡើងទៅមួយកម្រិតទៀត។ ពួកយើងមានសេចក្តីរីករាយជាពិសេស ដែលបានឃើញការរួមគ្នាដ៏រឹងមាំរវាងសមាគមមួយនេះ និងការងារ ដែលយើងទាំងអស់គ្នាបាននិងកំពុងធ្វើជាងមួយទសវត្សរ៍កន្លងមកហើយ ដើម្បីបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងកសាងបណ្តាញក្នុងចំណោមបុគ្គល និងអង្គការក្នុងវិស័យសិល្បៈ។

## កំណត់សម្គាល់សម្រាប់និពន្ធនាយក

- ឧស្សាហកម្មច្នៃប្រឌិត និងវប្បធម៌ គឺជាវិស័យទាំងឡាយ ដែលមានសកម្មភាពនិងគោលដៅចម្បងដូចជា ផលិតកម្ម ការផលិតឡើងវិញ ការលើកស្ទួយ ការចែកចាយទំនិញឬការធ្វើពាណិជ្ជកម្មទំនិញ សេវាកម្ម និងសកម្មភាពដែលមានខ្លឹមសារចេញពីប្រភពបេតិកភណ្ឌ សិល្បៈ និងវប្បធម៌។ ឧទាហរណ៍ដូចជា សិប្បកម្ម ភាពយន្ត សិល្បទស្សនីយភាព និងការរចនា។
- មូលនិធិអន្តរជាតិ សម្រាប់ភាពផ្សេងៗគ្នានៃវប្បធម៌ របស់អង្គការយូណេស្កូ គឺជាយន្តការមួយរបស់អនុសញ្ញា ស្តីពី ការការពារនិងលើកស្ទួយ ភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ (អនុសញ្ញា ឆ្នាំ ២០០៥)
- មូលនិធិអន្តរជាតិ សម្រាប់ភាពផ្សេងៗគ្នានៃវប្បធម៌ មានបំណងបង្កើតឱ្យមានវិស័យវប្បធម៌ដែលប្រកបដោយភាពរុងរឿងរស់រវើក និងលើកស្ទួយឱ្យមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងការកាត់បន្ថយភាពក្រីក្រ នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ រួមមានការអភិវឌ្ឍន៍

និងការអនុវត្តគោលនយោបាយវប្បធម៌ របស់ឧស្សាហកម្មវប្បធម៌ និងការកសាងសមត្ថភាព សម្រាប់សហគ្រិនវប្បធម៌ និងការបង្កើតគម្រូអាជីវកម្មនៃឧស្សាហកម្មវប្បធម៌ថ្មីមួយ។

- #SupportCreativity
- សិល្បៈខ្មែរអមតៈ ត្រូវបានបង្កើតឡើងដោយ លោក អាន ចនផន ក្នុងឆ្នាំ ១៩៩៨
- សិល្បៈខ្មែរអមតៈ គឺជាអង្គការឯករាជ្យ មិនស្វែងរកប្រាក់ចំណេញមួយ ដែលមានមូលដ្ឋាននៅក្នុងទីក្រុងភ្នំពេញ។
- សិល្បៈខ្មែរអមតៈមានបេសកកម្ម ដើរតួជាកត្តាជំរុញនៅក្នុងវិស័យសិល្បៈដ៏រស់រវើក ដែលញ៉ាំងចិត្តអ្នកជំនាន់ថ្មី។ សិល្បៈខ្មែរអមតៈ ជឿជាក់ថា សង្គមមួយអាចរីកចម្រើនពេញលេញទៅបានដោយមានការចូលរួមពីសិល្បៈ ហើយងមានទស្សនវិស័យថា សិល្បៈនិងវប្បធម៌មានសារៈសំខាន់ដែលមិនអាចខ្វះបានសម្រាប់អនាគតដ៏រុងរឿងរបស់កម្ពុជា។